ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ០៤០ គឃស.ប្រក/២១

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការដំឡើងឋានន្តរស័ក្តិ ឬថ្នាក់ ជូនមន្ត្រីរាជការស៊ីវិល តាមសាលាដំបូងខេត្តក្រុងជាន់ថ្នាក់ សម្រាប់ឆ្នាំ២០២១

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០០/១០៣ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២០/១៩៨ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឲ្យដំណើរការសាលាឧទ្ធរណ៍តំបន់

- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង
- យោងតាមតម្រូវការចាំបាច់របស់នាយកដ្ឋានកិច្ចការបុគ្គលិកនៃសាលាជម្រះក្ដី នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ ក្រសួងយុត្តិធម៌

## សម្រេច

**ប្រការ១ ..**

ត្រូវបានបង្កើតគណៈកម្មការដំឡើងឋានន្តរស័ក្តិ ឬថ្នាក់ជូនមន្ត្រីរាជការស៊ីវិល តាមសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់ សម្រាប់ឆ្នាំ២០២១ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ជិន ម៉ាលីន** | រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | ប្រធាន |
| ២-ឯកឧត្តម | **ផុច សំតី** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយកកិច្ចការរដ្ឋបាលតុលាការ | អនុប្រធាន |
| ៣-លោកជំទាវ | **អគ្គលេខាធិការ** | តុលាការកំពូល ឬតំណាង | សមាជិក/សមាជិកា |
| ៤-ឯកឧត្តម | **អគ្គលេខាធិការ** | សាលាឧទ្ធរណ៍ភ្នំពេញ ឬតំណាង | សមាជិក/សមាជិកា |
| ៥-ឯកឧត្តម លោកជំទាវ | **អគ្គលេខាធិការ** | សាលាឧទ្ធរណ៍តំបន់ ឬតំណាង | សមាជិក/សមាជិកា |
| ៦-លោក | **សៀខ គង់** | អគ្គនាយករងកិច្ចការរដ្ឋបាលតុលាការ | សមាជិក |
| ៧-លោក | **កេត ស៊ីណែត** | ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិកនៃសាលាជម្រះក្ដី | សមាជិក |
| ៨-លោក លោកស្រី | | ប្រធានលេខាធិការដ្ឋានរដ្ឋបាលសាលាជម្រះក្ដីរាជធានី-ខេត្ត | សមាជិក/សមាជិកា |
| ៩-លោក | **អែម ឈុនអេខ** | អនុប្រធាននាយកដ្ឋានកិច្ចការបុគ្គលិកនៃសាលាជម្រះក្ដី | សមាជិក |
| ១០-លោកស្រី | **ហួន សុគន្ធារី** | ប្រធានការិយាល័យធនធានមនុស្សនៃសាលាជម្រះក្ដី | លេខាធិការ |
| ១១-លោក | **សោម ចលនា** | អនុប្រធានការិយាល័យធនធានមនុស្សនៃសាលាជម្រះក្ដី | លេខាធិការ។ |

**ប្រការ២ ..**

គណៈកម្មការនេះមានភារកិច្ចដូចតទៅ៖

- ពិនិត្យ និងវាយតម្លៃសម្រេចក្នុងការដំឡើងឋានន្តរស័ក្តិ ឬថ្នាក់ តាមវេនអតីតភាព និងវេនជ្រើសរើស ឲ្យបានត្រឹមត្រូវ និងរៀបចំស្នើទៅក្រសួងមុខងារសាធារណៈឲ្យបានក្នុងអំឡុងខែមករា ឆ្នាំ២០២១
- ពិនិត្យ និងសម្រេចសុំដំឡើងថ្នាក់ ករណីពិសេសចំពោះមន្ត្រីរាជការដែលដល់អាយុចូលនិវត្តន៍
- ពិនិត្យ និងសម្រេចការស្នើសុំដំឡើងឋានន្តរស័ក្តិ ឬថ្នាក់ ជូនមន្ត្រីរាជការតាមកម្រិតនៃការបណ្តុះបណ្តាលដែលទទួលបានសញ្ញាប័ត្រខ្ពស់ជាងបន្ទាប់ដូចបានកំណត់ក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈ ដោយឡែកនៃក្របខ័ណ្ឌរបស់ខ្លួន និងមន្ត្រីរាជការដែលបានបញ្ចប់វគ្គវិក្រឹត្យការនៅសាលាភូមិន្ទរដ្ឋបាល
- រៀបចំស្នើសុំដំឡើងឋានន្តរស័ក្តិ ឬថ្នាក់ ប្រចាំឆ្នាំ តាមវេនអតីតភាព និងវេនជ្រើសរើសដាក់ជូនឯកឧត្តមរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងសម្រេច។

**ប្រការ៣ ..**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ អង្គភាពរដ្ឋបាលសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិកនៃសាលាជម្រះក្តី គ្រប់អង្គភាពពាក់ព័ន្ធ និងឯកឧត្តម លោកជំទាវ លោក លោកស្រី ដូចមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ១០កើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល :**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងមុខងារសាធារណៈ

**"ដើម្បីជូនជ្រាប"**

-ដូចប្រការ៣ **"ដើម្បីមុខការ"**

-ឯកសារ កាលប្បវត្តិ